# ច្បាប់
# ស្តីពី
# លក្ខន្តិកៈមន្ត្រីរាជការ នៃ
# ក្រុមនីតិប្បញ្ញត្តិ

អគ្គលេខាធិការដ្ឋាន (ព្រឹទ្ធសភា)
ចូល
លេខ...
ថ្ងៃទី... ម៉ោង...
បញ្ជូនទៅ...

# ព្រះរាជក្រម

នស/រកម/០២០៣/០០៧

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី លក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០៣ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាល ទី ២ ហើយដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៣ នាសម័យប្រជុំពេញអង្គលើកទី ៨ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ព្រះរាជក្រម

នស/រកម/០៤១៧/០០៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្តមិជាតិសាសនា រក្សាខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៣/០០៧ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាលើកទី៨ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៧ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖



## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១._ ថ្មី**

ច្បាប់នេះអនុវត្តចំពោះអ្នករាជការនៃក្រុមនីតិប្បញ្ញត្តិក្នុងក្រប-ខ័ណ្ឌណាមួយដែលមានចែងក្នុងមាត្រា ៥ ថ្មី នៃច្បាប់នេះ។

អ្នករាជការនៃក្រុមនីតិប្បញ្ញត្តិមានអ្នករាជការក្របខ័ណ្ឌរដ្ឋនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានរដ្ឋសភា។

ច្បាប់នេះក៏អនុវត្តចំពោះអ្នករាជការក្របខ័ណ្ឌរដ្ឋនៃអគ្គលេខា-ធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញផងដែរ។

**មាត្រា ២._**

អ្នករាជការនៃក្រុមនីតិប្បញ្ញត្តិ ត្រូវគោរពគោលការណ៍អព្យា-ក្រឹត មិនប្រកាន់គណបក្សនយោបាយក្នុងការបំពេញការងារ។

**មាត្រា ៣._**

អ្នករាជការអាចស្ថិតនៅក្រៅក្របខ័ណ្ឌដើមបាន។ បែបបទនៃការស្ថិតនៅក្រៅក្របខ័ណ្ឌដើមត្រូវកំណត់ដោយសេចក្តីសំរេចរបស់ប្រធានស្ថាប័ន។

**មាត្រា ៤._**

ក្នុងច្បាប់នេះ ពាក្យថា " ប្រធានស្ថាប័ន " សំដៅយកប្រធានស្ថាប័នណាមួយ ដែលអ្នករាជការធ្វើការក្នុងចំណោមស្ថាប័នទាំងបីដែលមានព្រឹទ្ធសភា រដ្ឋសភា និង ក្រុមប្រឹក្សាធម្មនុញ្ញ។

## ជំពូកទី ២
## ក្របខ័ណ្ឌ ឋានន្តរសក្តិ ថ្នាក់ និងមុខតំណែង

**មាត្រា ៥._ ថ្មី**

ក្របខ័ណ្ឌរបស់អ្នករាជការនៃក្រុមនីតិប្បញ្ញត្តិត្រូវបានបែងចែកជាបីប្រភេទគឺ៖

១- **ប្រភេទ ក** - ក្របខ័ណ្ឌអភិបាល

២- **ប្រភេទ ខ** - ក្របខ័ណ្ឌឧបការី

៣- **ប្រភេទ គ** - ក្របខ័ណ្ឌលេខាធិការ។

**មាត្រា ៦._ ថ្មី**

ក្របខ័ណ្ឌអភិបាលត្រូវបានបែងចែកជាបីឋានន្តរសក្តិដូចតទៅ៖

១-ឋានន្តរសក្តិទី ១ ឧត្តមអភិបាល

២-ឋានន្តរសក្តិទី ២ វរអភិបាល

៣-ឋានន្តរសក្តិទី ៣ អភិបាល។

**មាត្រា ៧._ ថ្មី**

ក្របខ័ណ្ឌឧបការីត្រូវបានបែងចែកជាបីឋានន្តរសក្តិដូចតទៅ៖

១-ឋានន្តរសក្តិទី ១ នាយឧបការី

២-ឋានន្តរសក្តិទី ២ ឧបការីដើមខ្សែ

៣-ឋានន្តរសក្តិទី ៣ ឧបការី។

**មាត្រា ៨._ ថ្មី**

ក្របខ័ណ្ឌលេខាធិការមានមួយឋានន្តរសក្តិ។

**មាត្រា ៩._ ថ្មី**

ថ្នាក់ក្នុងឋានន្តរសក្តិនៃប្រភេទក្របខ័ណ្ឌ **ក** ក្របខ័ណ្ឌ **ខ** និងក្របខ័ណ្ឌ **គ** ត្រូវកំណត់ដោយសេចក្តីសម្រេចរួមរបស់ប្រធានស្ថាប័នទាំងបី ។

**មាត្រា ១០._**

អ្នករាជការក្នុងក្របខ័ណ្ឌអភិបាលត្រូវមានសញ្ញាប័ត្រកំរិតអប្បបរមាបរិញ្ញាប័ត្រ និងមានឧបនិស្ស័យសម្រាប់កាន់មុខតំណែង

ដឹកនាំ សិក្សាស្រាវជ្រាវ ផ្តល់យោបល់ និងមុខងារក្នុងរាល់មុខតំណែងទទួលខុសត្រូវ។

អ្នករាជការក្នុងឋានន្តរសក្តិឧត្តមអភិបាលមានឧបនិស្ស័យសម្រាប់កាន់មុខតំណែងអគ្គនាយក អគ្គាធិការ និងមុខតំណែងឯទៀតដែលមានឋានៈស្មើ ឬខ្ពស់ជាង ហើយដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន។

អ្នករាជការក្នុងឋានន្តរសក្តិវរអភិបាល មានឧបនិស្ស័យសម្រាប់កាន់មុខតំណែងអគ្គនាយករង អគ្គាធិការរង និងប្រធាននាយកដ្ឋាន។

អ្នករាជការក្នុងឋានន្តរសក្តិអភិបាលមានឧបនិស្ស័យសម្រាប់កាន់មុខតំណែងអនុប្រធាននាយកដ្ឋាន។

**មាត្រា ១១.-**

អ្នករាជការក្នុងក្របខ័ណ្ឌឧបការីត្រូវមានសញ្ញាប័ត្រកំរិតអប្បបរមាសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិបូកវគ្គបណ្តុះបណ្តាលមុខវិជ្ជាជីវៈរយៈពេល ២ឆ្នាំ ដោយមានវិញ្ញាបនប័ត្រឬសញ្ញាប័ត្រ ។ អ្នករាជការក្នុងក្របខ័ណ្ឌឧបការីនេះ មានឧបនិស្ស័យសម្រាប់ជាជំនួយក្នុងការងារដល់មន្ត្រីគ្រប់គ្រងរដ្ឋបាល ដូចជារៀបចំការងារសម្រាប់អ្នកទទួលខុសត្រូវ ហើយអាចកាន់មុខតំណែងថ្នាក់ការិយាល័យ ឬផ្នែក។

អ្នករាជការក្នុងឋានន្តរសក្តិនាយឧបការី មានឧបនិស្ស័យសម្រាប់កាន់មុខតំណែងប្រធានការិយាល័យ។

អ្នករាជការក្នុងឋានន្តរសក្តិឧបការីដើមខ្សែ មានឧបនិស្ស័យសម្រាប់កាន់មុខតំណែងអនុប្រធានការិយាល័យ។

អ្នករាជការក្នុងឋានន្តរសក្តិឧបការី មានឧបនិស្ស័យសម្រាប់កាន់មុខតំណែងប្រធានផ្នែក។

**មាត្រា ១២._ ថ្មី**

អ្នករាជការក្នុងក្របខ័ណ្ឌលេខាធិការត្រូវមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ឬបានចូលរួមវគ្គបណ្តុះបណ្តាលមុខវិជ្ជាជីវៈកម្រិតបឋមដោយមានវិញ្ញាបនប័ត្រ ឬសញ្ញាប័ត្រ បញ្ជាក់ពីចំណេះបច្ចេកទេស ឬចំណេះធ្វើការងារជាក់លាក់ដែលជាតម្រូវការនៃស្ថាប័ន និងមានឧបនិស្ស័យសម្រាប់កាន់មុខតំណែងជាលេខាធិការក្នុងការិយាល័យ។

**មាត្រា ១៣._ ថ្មី**

អ្នករាជការអាចប្តូរក្របខ័ណ្ឌខ្ពស់ជាងបានតាមរយៈការប្រឡងប្តូរប្រភេទក្របខ័ណ្ឌផ្ទៃក្នុង ដូចមានចែងក្នុងមាត្រា ៣១ នៃច្បាប់នេះ។ ល័ក្ខខ័ណ្ឌនិងបែបបទនៃការប្រឡងប្តូរប្រភេទក្របខ័ណ្ឌត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានស្ថាប័ន។

**មាត្រា ១៤._**

អ្នករាជការដែលមានឋានន្តរសក្តិក្នុងមុខតំណែងណាមួយអាចត្រូវផ្លាស់ប្តូរទៅកាន់មុខតំណែងផ្សេងទៀតបាន។

**មាត្រា ១៥._**

សន្ទស្សន៍បៀវត្ស តម្លៃសន្ទស្សន៍ ប្រាក់បំណាច់ ប្រាក់វិភាជន៍គ្រួសារ ប្រាក់ព្យាបាលរោគ របបលាភការផ្សេងៗ បេឡាសោធននិវត្តន៍ បេឡាសោធនបាត់បង់សមត្ថភាពការងារ និងបេឡាជានារ៉ាប់រងសង្គម ត្រូវកំណត់ដោយសេចក្តីសម្រេចរួមរបស់ប្រធានស្ថាប័នទាំងបី។

**មាត្រា ១៦.-**

សញ្ញាសក្តិនិងឯកសណ្ឋានសម្រាប់អ្នករាជការនៃក្រុមនីតិប្បញ្ញត្តិត្រូវកំណត់ដោយព្រះរាជក្រឹត្យ។

## ជំពូកទី ៣
## ការជ្រើសរើសឱ្យចូលធ្វើការ

**មាត្រា ១៧.-**

ជាគោលការណ៍ រាល់ការជ្រើសរើសអ្នករាជការក្របខ័ណ្ឌណាមួយត្រូវធ្វើឡើងតាមការប្រឡងប្រជែង។

**មាត្រា ១៨.-**

បេក្ខជនទាំងពីរភេទត្រូវបំពេញល័ក្ខខ័ណ្ឌដូចខាងក្រោម ៖

១- មានសញ្ជាតិខ្មែរ

២- មានអាយុពី ១៨ឆ្នាំឡើងទៅ

៣- មានសំបុត្រថ្កោលទោស

៤- មានកិរិយាមារយាទល្អ

៥- មានកាយសម្បទា និងសមត្ថភាពសមស្របទៅនឹងសេចក្តីត្រូវការ។

**មាត្រា ១៩.-**

កាលបរិច្ឆេទនៃការប្រឡងជ្រើសរើសត្រូវផ្សព្វផ្សាយជាសាធារណៈឱ្យបាន៩០ថ្ងៃ មុនពេលប្រឡង។ ក្នុងករណីប្រញាប់ ការផ្សព្វផ្សាយត្រូវធ្វើយ៉ាងតិច ៣០ថ្ងៃមុន។

**មាត្រា ២០.- ថ្មី**

ការប្រឡងចូលក្របខ័ណ្ឌណាមួយ ត្រូវរៀបចំដោយគណៈកម្មការមួយដែលមានសមាសភាព ដូចខាងក្រោម ៖

១-អគ្គលេខាធិការ ឬតំណាង ប្រធាន
២-អគ្គនាយក ឬ/និងប្រធានអង្គភាពពាក់ព័ន្ធ សមាជិក
៣-ប្រធាននាយកដ្ឋានគ្រប់គ្រងបុគ្គលិក សមាជិក
៤-ប្រធាននាយកដ្ឋាន ឬប្រធានការិយាល័យពាក់ព័ន្ធ សមាជិក
៥-អ្នករាជការពីររូបក្នុងក្របខ័ណ្ឌជាមួយ សមាជិក។

**មាត្រា ២១.‗ ថ្មី**

អាចប្រឡងចូលក្របខ័ណ្ឌ នៃឋានន្តរសក្តិ ថ្នាក់ដំបូង ៖

-អភិបាល បេក្ខជនដែលមានសញ្ញាប័ត្រកម្រិតអប្បរមា បរិញ្ញាប័ត្រ ឬសញ្ញាប័ត្រមានតម្លៃស្មើ ។

-ឧបការី បេក្ខជនដែលមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ បូកវគ្គបណ្តុះបណ្តាលរយៈពេល ២ឆ្នាំ ដោយមានវិញ្ញាបនប័ត្រ ឬសញ្ញាប័ត្រ ។

-លេខាធិការ បេក្ខជនដែលមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ឬបានចូលរួមវគ្គបណ្តុះបណ្តាលមុខវិជ្ជាជីវៈកម្រិតបឋមដោយមានវិញ្ញាបនប័ត្រ ឬសញ្ញាប័ត្រ ។

**មាត្រា ២២.‗**

ផែនការតម្រូវការចំនួនអ្នករាជការប្រចាំឆ្នាំ ជាសមត្ថកិច្ចរបស់ប្រធានស្ថាប័ន តាមសំណើរបស់អគ្គលេខាធិការ ។

## ជំពូកទី ៤
## ការធ្វើកម្មសិក្សា ការតាំងស៊ប់ក្នុងក្របខ័ណ្ឌ ការបញ្ចេញពីក្របខ័ណ្ឌ

**មាត្រា ២៣.‗ ថ្មី**

រយៈពេលកម្មសិក្សាត្រូវកម្រិត ១២ខែ ដោយត្រូវគិតតាំងពីថ្ងៃតែងតាំងកម្មសិក្សាការីនោះ ។

កម្មសិក្សានេះមិនត្រូវយកជាការបានទេ បើកាលណាសាមីជនខកខានពុំបានមកធ្វើកម្មសិក្សាសរុប ៣០ថ្ងៃ។ ក្នុងករណីនេះ សាមី-ជនត្រូវបន្តធ្វើកម្មសិក្សានៅលើកទី២ ទៀត។ការបន្តធ្វើកម្មសិក្សាជាលើកទី២ ត្រូវមានរយៈពេលស្មើនឹងរយៈពេលលើកទី១ ដែរ ។

អ្នករាជការក្របខ័ណ្ឌចាស់ ដែលបានប្រឡងជាប់ទៅកាន់ក្របខ័ណ្ឌខ្ពស់ជាង មិនចាំបាច់ធ្វើកម្មសិក្សាឡើយ ។

**មាត្រា ២៤._ ថ្មី**

ការតាំងស៊ប់ត្រូវតែសម្រេចក្នុងរយៈពេលមិនលើសពី៣ខែក្រោយថ្ងៃផុតកំណត់រយៈពេលកម្មសិក្សា។

ការតាំងស៊ប់ចាប់ផ្តើមមានប្រសិទ្ធភាពខាងផ្នែកបៀវត្សក៏ដូចជាអតីតភាពការងារសម្រាប់ឡើងថ្នាក់ ។ ប៉ុន្តែអតីតភាពការងារសម្រាប់ចូលនិវត្តន៍ត្រូវបានគិតបញ្ចូលតាំងពីពេលចាប់ផ្តើមធ្វើកម្ម - សិក្សា ។

ការតាំងស៊ប់ត្រូវសម្រេចដោយប្រធានស្ថាប័នតាមសេចក្តីស្នើរបស់អគ្គលេខាធិការ ក្រោយពីមានការផ្តល់យោបល់ពីគណៈកម្មការមួយដែលមានសមាសភាពដូចតទៅ ៖

| | |
|---|---|
| ១-អគ្គលេខាធិការ ឬតំណាង | ប្រធាន |
| ២-អគ្គនាយក ឬ/និងប្រធានអង្គភាពពាក់ព័ន្ធ | សមាជិក |
| ៣-ប្រធាននាយកដ្ឋានគ្រប់គ្រងបុគ្គលិក | សមាជិក |
| ៤-ប្រធាននាយកដ្ឋាន ឬប្រធានការិយាល័យពាក់ព័ន្ធ | សមាជិក |
| ៥-អ្នករាជការ ២រូបដែលមានក្របខ័ណ្ឌដូចគ្នា | សមាជិក។ |

**មាត្រា ២៥.–**

កម្មសិក្សាការីណាដែលមិនមានសម្បទាវិជ្ជាជីវៈគ្រប់គ្រាន់ធ្វើការខ្ជីខ្ជា មិនគោរពវិន័យ ឬក៏គ្មានកម្លាំងពលំនឹងកាន់មុខតំណែងបាន អាចត្រូវបានបញ្ឈប់មិនឱ្យធ្វើការ ឬផ្ទេរទៅកាន់ក្របខ័ណ្ឌដើមវិញពេលណាក៏បាន ក្នុងរយៈពេលកម្មសិក្សា ។

**មាត្រា ២៦.– ថ្មី**

បៀវត្សរបស់កម្មសិក្សាការីត្រូវបានកាត់ទុកសម្រាប់ប្រាក់សោធននិវត្តន៍ ។ បើសិនជាកម្មសិក្សាការីមិនត្រូវបានតាំងស៊ប់ទេនោះ ប្រាក់ដែលបានកាត់ទុកសម្រាប់សោធននិវត្តន៍នោះ ត្រូវបានបង្វិលសងសាមីជនវិញទាំងអស់។

ក្នុងរយៈពេលកម្មសិក្សានេះ កម្មសិក្សាការីដែលជ្រើសរើសចេញពីសិស្ស និស្សិត ត្រូវបានផ្ដល់បៀវត្សមូលដ្ឋាននិងប្រាក់បំណាច់ផ្សេងៗ ដូចមានកំណត់ក្នុងសេចក្ដីសម្រេចរួមស្ដីពីបៀវត្សមូលដ្ឋាននិងប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ ។

**មាត្រា ២៧.– ថ្មី**

អ្នករាជការណាដែលធ្វើការតទៅទៀតមិនបាន ដោយហេតុមកពីបាត់បង់សម្បទាវិជ្ជាជីវៈហើយដែលមិនបានបំពេញល័ក្ខខ័ណ្ឌគ្រប់គ្រាន់ដើម្បីទទួលសោធននិវត្តន៍ ត្រូវបានចាត់ទុកថា បាត់បង់សមត្ថភាពការងារ ហើយត្រូវបញ្ឈប់មិនឱ្យធ្វើការតទៅទៀត។

ក្នុងករណីនេះ សាមីជនត្រូវបានទទួលប្រាក់ធានារ៉ាប់រងសង្គមម្ដងគត់ និងប្រាក់ដែលបានកាត់ទុកសម្រាប់សោធននិវត្តន៍។ បើអ្នក-រាជការនោះមានអតីតភាពការងារលើសពី ២០ឆ្នាំ សាមីជនត្រូវបានតម្រូវឱ្យចូលនិវត្តន៍ដោយបាត់បង់សម្បទាវិជ្ជាជីវៈ ដោយទទួលប្រាក់សោធននិវត្តន៍សមាមាត្រ ។

ការកំណត់ថាបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវសម្រេចដោយគណៈកម្មការមួយដែលមានសមាសភាពដូចខាងក្រោម ៖

១-អគ្គលេខាធិការ ឬតំណាង ប្រធាន

២-អគ្គនាយក ឬ/និងប្រធានអង្គភាពពាក់ព័ន្ធ សមាជិក

៣-ប្រធាននាយកដ្ឋានគ្រប់គ្រងបុគ្គលិក សមាជិក

៤-ប្រធាននាយកដ្ឋាន ឬប្រធានការិយាល័យពាក់ព័ន្ធ សមាជិក

៥-គ្រូពេទ្យដែលបានទទួលសញ្ញាប្រណិធាន និងដែលត្រូវបានចាត់ឡើងដោយក្រសួងសុខាភិបាល សមាជិក

៦-អ្នករាជការដែលមានក្របខ័ណ្ឌជាមួយគ្នា១នាក់ដែលមានឋានន្តរសក្តិយ៉ាងហោចណាស់ស្មើនឹងសាមីជន សមាជិក។

## ជំពូកទី ៥

## ការតែងតាំង ការតម្លើងឋានន្តរសក្តិ ថ្នាក់ និងគ្រឿងឥស្សរិយយស

**មាត្រា ២៨.–**

ការតែងតាំងអ្នករាជការឱ្យកាន់មុខតំណែងណាមួយ ត្រូវតែផ្អែកតាមអង្គការលេខនៃរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋានដែលមានកន្លែងទំនេរ ។

**មាត្រា ២៩.–**

ការតម្លើងថ្នាក់ជូនអ្នករាជការ ត្រូវធ្វើតាមវេនជ្រើសរើសក៏បាន ឬតាមវេនជ្រើសរើសនិងអតីតភាពជាមួយគ្នាក៏បាន។

**មាត្រា ៣០.–**

ការតម្លើងថ្នាក់ជូនអ្នករាជការ ត្រូវកំណត់តាមល័ក្ខខ័ណ្ឌដូចខាងក្រោម ៖

១- មានអតីតភាពការងារ ២ឆ្នាំ យ៉ាងតិច

២- មានលទ្ធផលល្អក្នុងការបំពេញការងារ

៣- គោរពវិន័យបានល្អ

៤- មានសាមគ្គីភាពផ្ទៃក្នុងល្អ។

ក្នុងករណីមានអ្នករាជការណាបំពេញការងារបានល្អវិសេស អ្នករាជ-ការនោះត្រូវបានតម្លើងថ្នាក់ជាស្វ័យប្រវត្តិ ដោយមិនគិតពីល័ក្ខខ័ណ្ឌអតីតភាពការងារឡើយ។

**មាត្រា ៣១._**

អ្នករាជការក្នុងក្របខ័ណ្ឌណាមួយអាចឡើងថ្នាក់បាន ម្តងមួយថ្នាក់។

នៅពេលអ្នករាជការត្រូវប្តូរក្របខ័ណ្ឌខ្ពស់ទៀតដោយសារបានប្រឡងជាប់សន្ទស្សន៍បៀវត្សត្រូវគិតតាមឋានន្តរសក្តិដំបូងនៃក្រប-ខ័ណ្ឌថ្មី។ ប៉ុន្តែបើបៀវត្សនៅទាបជាងបៀវត្សចាស់ ត្រូវរៀបត្រឹមថ្នាក់ដែលមានកំរិតស្មើ ឬខ្ពស់បន្ទាប់ពីសន្ទស្សន៍បៀវត្សក្របខ័ណ្ឌចាស់នៃអ្នករាជការនោះ ។ អតីតភាពការងារដើម្បីតម្លើងថ្នាក់ត្រូវគិតពីថ្ងៃដែលបានទទួលបៀវត្សថ្នាក់ចុងក្រោយ។

ការតម្លើងថ្នាក់ត្រូវសម្រេចដោយប្រធានស្ថាប័ន និងស្របតាមកំរិតមុខចំណាយថវិកា។

**មាត្រា ៣២._ ថ្មី**

នៅពេលតម្លើងថ្នាក់ដោយប្តូរឋានន្តរសក្តិ អ្នករាជការក្នុងថ្នាក់ខ្ពស់បំផុតនៃឋានន្តរសក្តិទី ៣ និងឋានន្តរសក្តិទី ២ នៃគ្រប់ក្របខ័ណ្ឌត្រូវបានតម្លើងឋានន្តរសក្តិទៅថ្នាក់ដំបូងនៃឋានន្តរសក្តិខ្ពស់បន្ទាប់។

**មាត្រា ៣៣._ ថ្មី**

ការតម្លើងថ្នាក់ត្រូវកំណត់យក ៣ ភាគ ៤ (៣/៤) តាមវេនជ្រើសរើស និង១ ភាគ ៤ (១/៤) តាមវេនអតីតភាពការងារ នៃគ្រប់ឋានន្តរសក្តិ និងគ្រប់ក្របខ័ណ្ឌ ។ លើសពីនេះ ការតម្លើងថ្នាក់ត្រូវធ្វើឡើងដោយការជ្រើសរើស ។

**មាត្រា ៣៤._ ថ្មី**

អ្នករាជការក្របខ័ណ្ឌអភិបាលដែលមានសញ្ញាប័ត្រខ្ពស់ជាងបរិញ្ញាប័ត្រត្រូវបានតម្លើងថ្នាក់ ១ថ្នាក់ជាស្វ័យប្រវត្តិ ។

អ្នករាជការក្របខ័ណ្ឌឧបការីដែលមានបរិញ្ញាប័ត្រ ឬសញ្ញា-ប័ត្រមានតម្លៃស្មើ ត្រូវបានតម្លើងថ្នាក់ ១ថ្នាក់ជាស្វ័យប្រវត្តិ ។

អ្នករាជការក្របខ័ណ្ឌលេខាធិការដែលមានសញ្ញាប័ត្រខ្ពស់ជាងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ត្រូវបានតម្លើងថ្នាក់ ១ថ្នាក់ជាស្វ័យប្រវត្តិ។

អ្នករាជការដែលត្រូវបានតម្លើងថ្នាក់តាមសញ្ញាប័ត្រដូចមានចែងក្នុងកថាខ័ណ្ឌខាងលើ ត្រូវរក្សាទុកអតីតភាពសម្រាប់តម្លើងថ្នាក់ប្រចាំឆ្នាំតាមវេនជ្រើសរើស ឬតាមវេនអតីតភាព។

**មាត្រា ៣៥._ ថ្មី**

ជារៀងរាល់ឆ្នាំនៅខែមករា នាយកដ្ឋានគ្រប់គ្រងបុគ្គលិកត្រូវចុះបញ្ជីអ្នករាជការដែលត្រូវពិនិត្យតម្លើងថ្នាក់ទាំងអស់ ហើយបញ្ជូនព្រឹត្តិប័ត្រពិន្ទុដល់អ្នករាជការទាំងអស់នោះឱ្យបំពេញ រួចបញ្ជូនទៅការិយាល័យ នាយកដ្ឋាន អគ្គនាយកដ្ឋាន ឬអង្គភាពសាមី ដើម្បីដាក់ពិន្ទុ និងចុះមូលវិចារណ៍។ បន្ទាប់ពីដាក់ពិន្ទុ និងចុះមូលវិចារណ៍រួចហើយ

អគ្គនាយក ឬប្រធានអង្គភាពសាមី ត្រូវបញ្ជូនព្រឹត្តិប័ត្រពិន្ទុនោះទៅនាយកដ្ឋានគ្រប់គ្រងបុគ្គលិកវិញ ដើម្បីធ្វើបញ្ជីចំណាត់ថ្នាក់រួម ឬដោយឡែកតាមអគ្គនាយកដ្ឋាន ឬអង្គភាពសាមី ឬតាមក្របខ័ណ្ឌសម្រាប់រាយការណ៍ជូនគណៈកម្មការតម្លើងថ្នាក់នៅពេលប្រជុំ។

រាល់ទំនាក់ទំនងការងារ និងការវាយតម្លៃខាងលើនេះ ត្រូវធ្វើដោយសម្ងាត់ ។

**មាត្រា ៣៦._ ថ្មី**

អគ្គលេខាធិការបញ្ឈប់បញ្ជីអ្នករាជការដែលត្រូវបានស្នើពិនិត្យតម្លើងថ្នាក់រួចបញ្ជូនទៅគណៈកម្មការតម្លើងថ្នាក់ដើម្បីធ្វើការប្រជុំ។

សមាសភាពគណៈកម្មការតម្លើងថ្នាក់មានដូចតទៅ ៖

| | |
|---|---|
| ១-អគ្គលេខាធិការ ឬតំណាង | ប្រធាន |
| ២-អគ្គនាយក ឬ/ និងប្រធានអង្គភាពពាក់ព័ន្ធ | សមាជិក |
| ៣-ប្រធាននាយកដ្ឋានគ្រប់គ្រងបុគ្គលិក | សមាជិក |
| ៤-ប្រធាននាយកដ្ឋាន ឬប្រធានការិយាល័យពាក់ព័ន្ធ | សមាជិក |
| ៥-អ្នករាជការដែលមានក្របខ័ណ្ឌជាមួយគ្នា ២នាក់ | សមាជិក។ |

**មាត្រា ៣៧._**

ការតម្លើងថ្នាក់ត្រូវធ្វើនៅខែមេសានៃឆ្នាំនីមួយៗ ។

អ្នកដែលមានឈ្មោះក្នុងបញ្ជី ប៉ុន្តែមិនបានឡើងថ្នាក់ មានអាទិភាពក្នុងការតម្លើងថ្នាក់នាឆ្នាំបន្ទាប់ លើកលែងតែគណៈកម្មការសម្រេចផ្ទុយពីនេះ ដោយមានសេចក្តីរាយការណ៍សមហេតុផល និងមានការយល់ព្រមពីអគ្គលេខាធិការ ។ អ្នករាជការម្នាក់ៗមានសិទ្ធិសុំមើលដោយស្ងាត់កំបាំងនូវកំណត់ហេតុ និងឯកសារឯទៀតៗ

ដែលជាសំណុំរឿងផ្ទាល់ខ្លួន ដើម្បីការពារខ្លួន នៅពេលដែលខ្លួនពុំបានឡើងថ្នាក់តាមវេនអតីតភាព ។

**មាត្រា ៣៨._**

សិទ្ធិឡើងថ្នាក់ត្រូវផ្អាកទុកសិនចំពោះអ្នករាជការណាដែលទទួលទណ្ឌកម្មថ្នាក់ទី២ ខាងវិន័យ ឬទទួលការចោទប្រកាន់តាមផ្លូវតុលាការ និងអ្នកដែលត្រូវបានដាក់ឱ្យនៅទំនេរគ្មានបៀវត្សចាប់ពីរយៈពេល ៦ខែ ឡើងទៅ ។

**មាត្រា ៣៩._**

អ្នករាជការដែលមានស្នាដៃល្អក្នុងការបំពេញការងារ អាចទទួលគ្រឿងឥស្សរិយយស។

ល័ក្ខខ័ណ្ឌ និងបែបបទនៃការផ្តល់គ្រឿងឥស្សរិយយស ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានស្ថាប័ន ។

ឋានន្តរសក្តិកិត្តិយសអាចផ្តល់ដោយប្រធានស្ថាប័នជូនអ្នករាជការចូលនិវត្តន៍ ឬលាលែង ឬដាក់ឱ្យឈប់ធ្វើការដោយបាត់បង់សមត្ថភាពការងារ ឬទទួលមរណភាព បន្ទាប់ពីបានបំពេញការងារអស់រយៈពេលយូរ និងមានស្នាដៃល្អ ។

## ជំពូកទី ៦
## ការឈប់សម្រាក

**មាត្រា ៤០._**

អ្នករាជការមានសិទ្ធិឈប់សម្រាកប្រចាំឆ្នាំចំនួន ១៥ថ្ងៃ បន្ថែមពីលើថ្ងៃឈប់សម្រាកដែលកំណត់ដោយរាជរដ្ឋាភិបាល។

អ្នករាជការនារី មានសិទ្ធិឈប់សម្រាកលំហែមាតុភាពចំនួន ៩០ថ្ងៃ។

អ្នករាជការដែលមានធុរៈអាចត្រូវបានអនុញ្ញាតច្បាប់ឱ្យឈប់សម្រាកពីការងារ ។

**មាត្រា ៤១.-**

អ្នករាជការដែលមានអតីតភាពការងារយ៉ាងតិច ៥ឆ្នាំ មានសិទ្ធិសុំឈប់ទំនេរដោយគ្មានបៀវត្ស ដែលមានរយៈពេលសរុបទាំងអស់ចំនួន ៤ឆ្នាំ។

បែបបទ ល័ក្ខខ័ណ្ឌនិងរយៈពេលនៃការឈប់នេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានស្ថាប័ន។

## ជំពូកទី ៧
## វិន័យ

**មាត្រា ៤២.-**

អ្នករាជការរាល់រូបត្រូវប្រតិបត្តិតាមច្បាប់ និងបទបញ្ជាហើយគោរពថ្នាក់លើរបស់ខ្លួន។

អ្នករាជការត្រូវទទួលខុសត្រូវចំពោះថ្នាក់លើអំពីកិច្ចការនិងអំពើរបស់ខ្លួនដែលបានធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរនិងកិត្តិយសនៃអ្នករាជការ ទោះបីកិច្ចការនោះប្រព្រឹត្តនៅមជ្ឈដ្ឋានខាងក្រៅក៏ដោយ។

**មាត្រា ៤៣.-**

អ្នករាជការរាល់រូបមិនអាចអវត្តមានដោយគ្មានការអនុញ្ញាត ឬដោយគ្មានមូលហេតុត្រឹមត្រូវបានឡើយ។

អវត្តមានដោយគ្មានការអនុញ្ញាត ឬដោយគ្មានមូលហេតុត្រឹមត្រូវអាចឱ្យអ្នករាជការនោះទទួលទណ្ឌកម្មខាងវិន័យ។

**មាត្រា ៤៤._**

អ្នករាជការមិនត្រូវ ៖

- យកម៉ោងរដ្ឋបាលទៅប្រកបមុខរបរផ្ទាល់ខ្លួន
- ប្រើឥទ្ធិពលនិងអំណាចក្នុងមុខងាររបស់ខ្លួន ដើម្បីទាញយកផលប្រយោជន៍អ្វីមួយ ឬសំឡុតគំរាមកំហែងបំពានសិទ្ធិរបស់ពលរដ្ឋ
- ប្រកបមុខរបរណាដែលនាំឱ្យប៉ះពាល់កិត្តិយសនិងសេចក្តីថ្លៃថ្នូររបស់អ្នករាជការ
- ចូលជាសមាជិកក្រុមប្រឹក្សាភិបាល ឬគ្រប់គ្រងក្រុមហ៊ុនឯកជនដោយផ្ទាល់ ឬដោយប្រយោល
- បោះពុម្ពផ្សាយឬផ្សព្វផ្សាយព័ត៌មានដែលទាក់ទងនឹងការងាររបស់អគ្គលេខាធិការដ្ឋានឬការងាររបស់ស្ថាប័នដោយគ្មានការអនុញ្ញាតជាមុន។

អំពើបំពាននឹងបទប្បញ្ញត្តិនៃមាត្រានេះ អាចបណ្តាលឱ្យទទួលទណ្ឌកម្មផ្នែកវិន័យណាមួយដែលមានចែងក្នុងមាត្រា ៤៧ នៃច្បាប់នេះ ដោយមិនទាន់គិតដល់ការចោទប្រកាន់ជាបទអាជ្ញាដែលអាចកើតមានឡើងទៀតផង ។

**មាត្រា ៤៥._**

ហាមដាច់ខាតការប្រើមុខងាររបស់ខ្លួន ចលនទ្រព្យ អចលនទ្រព្យ និងថវិការបស់រដ្ឋដើម្បីបំរើផលប្រយោជន៍ ឬប្រឆាំងនឹងសមាជិកឬគណបក្សនយោបាយណាមួយ។

អំពើបំពានមាត្រានេះជាកំហុសឆ្គងខាងវិជ្ជាជីវៈ ហើយត្រូវទទួលទណ្ឌកម្មខាងវិន័យ។

**មាត្រា ៤៦.-**

មុខងារអ្នករាជការនៃក្រុមនីតិប្បញ្ញត្តិមានវិសមិតភាពជាមួយការប្រកបវិជ្ជាជីវៈជាមេធាវី ជាចៅក្រមក្នុងតំណែង ជាសមាជិកក្រុមប្រឹក្សាភិបាលសហគ្រាសសាធារណៈ ជាថ្នាក់ដឹកនាំគណបក្សនយោ-បាយ និងមុខងារជាអ្នករាជការក្នុងមុខងារសាធារណៈ។

អំពើបំពានមាត្រានេះត្រូវទទួលទណ្ឌកម្មខាងវិន័យថ្នាក់ទី២។

**មាត្រា ៤៧.-**

ទណ្ឌកម្មខាងវិន័យមានដូចតទៅ ៖

**១- ទណ្ឌកម្មថ្នាក់ទី ១**

ក- ស្តីបន្ទោស

ខ- ស្តីបន្ទោសដោយមានចុះចំណាំក្នុងសំណុំលិខិតផ្ទាល់ខ្លួន

គ- ផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យ

**២- ទណ្ឌកម្មថ្នាក់ទី ២**

ក- លុបឈ្មោះចេញពីបញ្ជីតម្លើងថ្នាក់បើសិនជាមានចុះឈ្មោះ ហើយ ឬមិនតម្លើងថ្នាក់ក្នុងថេរវេលាមួយមិនលើសពី ២ឆ្នាំ

ខ- ដាក់ឱ្យនៅទំនេរគ្មានបៀវត្សមិនឱ្យលើសពី ១ឆ្នាំ

គ- បន្ថយឋានន្តរសក្តិ ឬថ្នាក់មួយថ្នាក់ ឬច្រើនថ្នាក់

ឃ- ដាក់ឱ្យចូលនិវត្តន៍មុនកំណត់ ឬបញ្ឈប់ពីការងារដោយបង្ខំ

ង- បណ្តេញចេញពីមុខតំណែងរាជការ ។

**មាត្រា ៤៨.-**

រាល់ទណ្ឌកម្មថ្នាក់ទី១ និងចំណុច(ក) នៃទណ្ឌកម្មថ្នាក់ទី២ ត្រូវសម្រេចដោយអគ្គលេខាធិការ ក្រោយពីមានយោបល់របស់ក្រុមប្រឹក្សាវិន័យ ។

**មាត្រា ៤៩.-**

រាល់ទណ្ឌកម្មដទៃទៀតនៃទណ្ឌកម្មថ្នាក់ទី២ ត្រូវសម្រេចដោយប្រធានស្ថាប័នតាមសេចក្តីស្នើរបស់អគ្គលេខាធិការ។

**មាត្រា ៥០.-**

អ្នករាជការដែលត្រូវបានបន្ថយថ្នាក់ ឬឋានន្តរសក្តិត្រូវទទួលឋានន្តរសក្តិថ្មី និងបៀវត្សថ្មី ចាប់ពីថ្ងៃដែលបានសម្រេច។ អ្នករាជការនោះនឹងអាចជាប់ឈ្មោះក្នុងបញ្ជីតម្លើងថ្នាក់បាន លុះត្រាតែបំពេញការងារគ្រប់អតីតភាពការងារដែលបានកំណត់សាជាថ្មី មិនអាចយកអតីតភាពការងារដែលខ្លួនបានបំពេញពីមុនបន្ថយថ្នាក់ ឬឋានន្តរសក្តិមកគិតផ្សំជាមួយរយៈពេលដែលបានបំពេញក្នុងថ្នាក់ ឬឋានន្តរសក្តិថ្មីនេះផងបានទេ ។

**មាត្រា ៥១.-**

ការបណ្តេញអ្នករាជការចេញពីមុខតំណែងដូចមានចែងក្នុងមាត្រា៤៧ ទណ្ឌកម្មទី២(ង) គឺការដកមុខងារនិងឋានន្តរសក្តិដែលបានប្រគល់ឱ្យពីមុនដល់អ្នករាជការនោះ។ ក្នុងករណីនេះ អ្នករាជការនោះមានសិទ្ធិទទួលមកវិញទាំងអស់នូវប្រាក់ដែលបានកាត់ទុកក្នុងបេឡាសោធននិវត្តន៍។

**មាត្រា ៥២.-**

ការដាក់វិន័យត្រូវធ្វើតាមសេចក្តីសម្រេចរបស់សមត្ថកិច្ចដែលមានចែងក្នុងមាត្រា ៤៨ និង មាត្រា ៤៩។

**មាត្រា ៥៣.–**

សេចក្តីសម្រេចចោទប្រកាន់ដើម្បីដាក់វិន័យ តម្រូវឱ្យមានការផ្អាកការងារនៃអ្នករាជការនោះជាបណ្តោះអាសន្ន តែមិនអាចផ្អាកបៀវត្សរ៍ទេ។ ក្នុងរយៈពេលមួយខែយ៉ាងយូរ ក្រុមប្រឹក្សាវិន័យត្រូវកោះប្រជុំផ្តល់យោបល់ ។

ការផ្អាកការងារអ្នករាជការជាបណ្តោះអាសន្នមានកំណត់ត្រឹមបីខែ ប៉ុន្តែបើជាករណីពិសេសអាចបន្តជាថ្មីទៀតបានគឺកំណត់មួយខែម្តង ប៉ុន្តែការបន្តនោះ មិនត្រូវលើសពីបីដងឡើយ។

**មាត្រា ៥៤.–**

ការចោទប្រកាន់ដើម្បីដាក់វិន័យត្រូវចាប់ធ្វើអង្កេតជាមុនសិន។

**មាត្រា ៥៥.–**

ការធ្វើអង្កេតជាដំបូងត្រូវប្រគល់ឱ្យតំណាងអគ្គលេខាធិការមួយរូប ឬច្រើនរូប ដែលមានឋានន្តរសក្តិ និងថ្នាក់ខ្ពស់ជាង ហើយមានអតីតភាពការងារយ៉ាងតិចស្មើនឹងអ្នកដែលត្រូវជាប់ចោទ ។

សំណុំរឿងត្រូវបញ្ជូនទៅអគ្គលេខាធិការដើម្បីពិនិត្យនិងសម្រេចថាគួរបញ្ជូនអ្នករាជការជាប់ចោទនោះទៅឱ្យក្រុមប្រឹក្សាវិន័យ ឬសម្រេចថាគួរបញ្ចប់ការចោទប្រកាន់វិញ ។ ក្នុងករណីដែលអគ្គ-លេខាធិការយល់ឃើញថាគួរបន្តចោទប្រកាន់សំណុំរឿងត្រូវបញ្ជូនទៅឱ្យក្រុមប្រឹក្សាវិន័យ ។ ក្រុមប្រឹក្សាវិន័យត្រូវអញ្ជើញអ្នករាជការជាប់ចោទមកពន្យល់ដោះសាដោយផ្ទាល់មាត់ និងលាយលក្ខណ៍អក្សរ មុននឹងធ្វើការសន្និដ្ឋាន ជូនយោបល់ដល់ថ្នាក់មានសមត្ថកិច្ចសម្រេចអំពីកំហុសនិងទណ្ឌកម្ម។

**មាត្រា ៥៦._ ថ្មី**

ត្រូវបានបង្កើតក្រុមប្រឹក្សាវិន័យដែលមានសមាសភាព ៖

១-អគ្គលេខាធិការ ឬតំណាង ប្រធាន

២-អគ្គនាយក ឬ/ និងប្រធានអង្គភាពពាក់ព័ន្ធ សមាជិក

៣-ប្រធាននាយកដ្ឋានគ្រប់គ្រងបុគ្គលិក សមាជិក

៤-ប្រធាននាយកដ្ឋាន ឬប្រធានការិយាល័យនៃ អ្នករាជការជាប់ចោទ សមាជិក

៥-អ្នករាជការចំនួន ២ ឬ ៣នាក់ ដែលមានក្របខ័ណ្ឌដូចគ្នាតែមានអតីតភាពការងារច្រើនជាង សមាជិក។

មិនអាចចាត់ឱ្យចូលក្នុងក្រុមប្រឹក្សាវិន័យនេះបាន អ្នករាជការណាដែលជាអ្នកធ្វើសេចក្តីរាយការណ៍ ឬពាក្យបណ្តឹងចំពោះអ្នករាជការជាប់ចោទ ឬសាច់ញាតិរហូតដល់ថ្នាក់ទី៣ នៃអ្នករាជការជាប់ចោទ។

**មាត្រា ៥៧._**

ក្រោយពេលដែលក្រុមប្រឹក្សាវិន័យត្រូវបានបង្កើតរួចហើយ ប្រធានក្រុមប្រឹក្សាវិន័យត្រូវបញ្ជូនសំណុំរឿងទាំងនោះ ឱ្យទៅប្រធាននាយកដ្ឋានគ្រប់គ្រងបុគ្គលិក។ ប្រធាននាយកដ្ឋានគ្រប់គ្រងបុគ្គលិកអាចរកព័ត៌មានបន្ថែមទៀតបានក្នុងការស្វែងរកការពិត ។ ប្រធាននាយកដ្ឋានគ្រប់គ្រងបុគ្គលិកត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរពីលទ្ធផលអង្កេតរបស់ខ្លួន ដោយមិនបញ្ចេញយោបល់ផ្ទាល់ខ្លួនថាគួរសម្រេចយ៉ាងណាៗទេ ហើយបញ្ជូនសេចក្តីរាយការណ៍នេះឱ្យទៅប្រធានក្រុមប្រឹក្សាវិន័យ ។

**មាត្រា ៥៨._**

ក្រុមប្រឹក្សាវិន័យប្រជុំតាមការអញ្ជើញរបស់ប្រធាន។ អ្នករាជការជាប់ចោទព្រមទាំងសាក្សីនៃគ្រប់ភាគី ត្រូវចូលខ្លួនតាមសេចក្តីអញ្ជើញរបស់ក្រុមប្រឹក្សាវិន័យ ។ អ្នកជាប់ចោទត្រូវរាយការណ៍ដោយផ្ទាល់មាត់ និងដោយលាយលក្ខណ៍អក្សរជូនក្រុមប្រឹក្សាវិន័យនូវចំណុចដែលក្រុមប្រឹក្សាវិន័យចោទសួរ ។

ប្រធាននាយកដ្ឋានគ្រប់គ្រងបុគ្គលិកត្រូវធ្វើកំណត់ហេតុឱ្យបានច្បាស់លាស់ ត្រឹមត្រូវតាមខ្លឹមសារនៃអង្គប្រជុំ ។

**មាត្រា ៥៩._**

ក្រោយពីបានសាកសួរនិងពិនិត្យឯកសារចប់សព្វគ្រប់ ក្រុម-ប្រឹក្សាវិន័យថយទៅវិនិច្ឆ័យរឿងកំបាំងមុខពីសាមីជន។ការវិនិច្ឆ័យនេះត្រូវសម្រេចដោយការបោះឆ្នោតជាសម្ងាត់ តាមសំលេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកក្រុមប្រឹក្សាវិន័យ ។

យោបល់សម្រេចរបស់ក្រុមប្រឹក្សាវិន័យ ត្រូវប្រកាសឱ្យសាមីជនដឹងភ្លាមដើម្បីធ្វើការតវ៉ា ហើយរាយការណ៍ទៅថ្នាក់មានសមត្ថកិច្ច។ បើហួសរយៈពេល១៥ថ្ងៃ សាមីជនមិនតវ៉ា សេចក្តីសម្រេចរបស់ក្រុម-ប្រឹក្សាវិន័យត្រូវបញ្ជូនទៅថ្នាក់មានសមត្ថកិច្ចដើម្បីសម្រេច។

**មាត្រា ៦០._**

ប្រធានក្រុមប្រឹក្សាវិន័យអាចពន្យារពេលប្រជុំទៅថ្ងៃក្រោយបានព្រមទាំងអាចចាត់វិធានការផ្សេងៗ ដែលមានសារប្រយោជន៍ដើម្បីរកការពិត និងកុំប៉ះពាល់ដល់សេចក្តីវិនិច្ឆ័យរបស់តុលាការ ក្នុងករណីដែលតុលាការបានសម្រេចជាមុនរួចហើយ។

**មាត្រា ៦១.‒**

បែបបទនៃការតវ៉ា នីតិវិធីនៃការដោះស្រាយការតវ៉ា និងនីតិវិធីនៃការអនុវត្តវិន័យ ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធានស្ថាប័ន ។

អ្នករាជការមានសិទ្ធិប្ដឹងទៅតុលាការ បើសិនជាមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់ប្រធានស្ថាប័ន ទោះក្នុងករណីណាក៏ដោយ។

## ជំពូកទី ៨

## ការចោទប្រកាន់តាមផ្លូវតុលាការ

**មាត្រា ៦២.‒**

អ្នករាជការដែលត្រូវបានតុលាការកំពុងចោទប្រកាន់ ហើយដែលត្រូវបានបញ្ជូនខ្លួនឱ្យតុលាការជំនុំជំរះ អាចត្រូវបានផ្អាកការងារសិនក្នុងករណីចាំបាច់ ។

ក្នុងករណីមានការចាប់ខ្លួន ឬការឃាត់ខ្លួន ឬការឃុំឃាំងខ្លួនជាបណ្ដោះអាសន្នលើអ្នករាជការណាម្នាក់នោះ ព្រះរាជអាជ្ញា ឬចៅក្រមមានសមត្ថកិច្ច ត្រូវរាយការណ៍ជាបន្ទាន់ទៅប្រធានស្ថាប័នសាមីក្នុងរយៈពេល ៧២ម៉ោងយ៉ាងយូរ ។

ក្នុងករណីដែលបទល្មើសនោះកើតមានក្នុងក្របខ័ណ្ឌនៃការបំរើការងារសាធារណៈ ប្រធានស្ថាប័នសាមីត្រូវការពារអ្នករាជការនោះតាមផ្លូវច្បាប់ ។

**មាត្រា ៦៣.‒**

ក្នុងករណីដែលអ្នករាជការត្រូវបានផ្អាកពីការងារបណ្ដាលមកពីជាប់ចោទតាមផ្លូវតុលាការជាបទមជ្ឈឹម ឬបទឧក្រិដ្ឋ ហើយត្រូវបាន

តុលាការសម្រេចថា គ្មានទោស អ្នករាជការនោះត្រូវបានឱ្យចូលធ្វើការវិញភ្លាម ដោយបានមកវិញទាំងអស់ ទាំងអតីតភាពការងារ និងទាំងឋានន្តរសក្តិ ។

ក្នុងករណីនេះអ្នករាជការជាប់ចោទ អាចត្រូវទទួលទណ្ឌកម្មខាងវិន័យបានទៀត បើពិនិត្យឃើញថា មានការផ្គាំផ្គងដូចជាការធ្វេសប្រហែស ការប៉ះពាល់កិត្តិយស និងសេចក្តីថ្លៃថ្នូរ។

**មាត្រា ៦៤.–**

អ្នករាជការដែលតុលាការបានកាត់ទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋត្រូវលុបឈ្មោះចេញពីស្ថាប័ន ចាប់ពីថ្ងៃដែលតុលាការចេញសេចក្តីសម្រេចជាស្ថាពរ ។

## ជំពូកទី ៩

## ការចូលនិវត្តន៍

**មាត្រា ៦៥.– ថ្មី**

អ្នករាជការនៃក្រុមនីតិប្បញ្ញត្តិត្រូវបានដាក់ឱ្យចូលនិវត្តន៍តាមល័ក្ខខ័ណ្ឌអាយុដូចខាងក្រោម ៖

-៦០ឆ្នាំ សម្រាប់ក្របខ័ណ្ឌអភិបាល (ប្រភេទ ក)

-៥៨ឆ្នាំ សម្រាប់ក្របខ័ណ្ឌឧបការី (ប្រភេទ ខ)

-៥៥ឆ្នាំ សម្រាប់ក្របខ័ណ្ឌលេខាធិការ (ប្រភេទ គ )។

អ្នករាជការក្របខ័ណ្ឌអភិបាល ក្របខ័ណ្ឌឧបការី និងក្របខ័ណ្ឌលេខាធិការ ដែលដល់អាយុចូលនិវត្តន៍ អាចអនុញ្ញាតឱ្យបន្តការងារបានតាមសេចក្តីស្នើរបស់សាមីខ្លួន និងតាមសេចក្តីសម្រេចរបស់ប្រធានស្ថាប័ន ។ ការបន្តការងារនេះមានរយៈពេល ១ឆ្នាំម្តង ប៉ុន្តែមិនឱ្យលើសពីបីដងឡើយ។

គោលការណ៍ និងនីតិវិធីនៃការដាក់ឱ្យអ្នករាជការចូលនិវត្តន៍ ត្រូវកំណត់ដោយសេចក្តីសម្រេចរួមរបស់ប្រធានស្ថាប័នទាំងបី ។

**មាត្រា ៦៦.-**

អ្នករាជការដែលដល់អាយុចូលនិវត្តន៍ ហើយមានអតីតភាពការងារក្នុងចន្លោះពី ២០ឆ្នាំ ដល់ក្រោម ៣០ឆ្នាំ ត្រូវបានទទួលប្រាក់សោធននិវត្តន៍សមាមាត្រ ។

**មាត្រា ៦៧.-**

អ្នករាជការដែលដល់អាយុចូលនិវត្តន៍ ហើយដែលមានអតីត-ភាពការងារ ៣០ឆ្នាំយ៉ាងតិច ត្រូវបានទទួលប្រាក់សោធននិវត្តន៍អតីតភាព។ ប៉ុន្តែអ្នករាជការដែលបានបម្រើការងាររយៈពេល ៣០ឆ្នាំ អាចសុំចូលនិវត្តន៍មុនដល់អាយុត្រូវចូលនិវត្តន៍បាន ដោយត្រូវបានទទួលប្រាក់សោធននិវត្តន៍អតីតភាព ។

**មាត្រា ៦៨.-**

អ្នករាជការដែលបានបំរើការងារក្រោម ២០ឆ្នាំ ហើយដល់អាយុចូលនិវត្តន៍ត្រូវទទួលប្រាក់សោធននិវត្តន៍ដែលបានកាត់ទុក និងប្រាក់ឧបត្ថម្ភផ្សេងៗ តែមួយលើក ។

**មាត្រា ៦៩.-**

ចំពោះអ្នករាជការដែលមានអតីតភាពការងារគ្រប់ ៣០ឆ្នាំហើយ ហើយមិនទាន់ដល់អាយុចូលនិវត្តន៍ទេនោះ មិនត្រូវបានកាត់ទុកប្រាក់សោធននិវត្តន៍ឡើយ ។

**មាត្រា ៧០.-**

អតីតភាពការងារសម្រាប់ចូលនិវត្តន៍របស់អ្នករាជការ ត្រូវគិតតាំងពីថ្ងៃដែលសាមីជនចូលបំរើការងាររដ្ឋ ទោះក្នុងសម័យណាក៏ដោយ។

## ជំពូកទី ១០
## បទប្បញ្ញត្តិដោយឡែក

**មាត្រា ៧១._**

ផ្អែកលើការចាំបាច់ ប្រធានស្ថាប័នអាចតែងតាំងមន្ត្រីចាំបាច់មួយចំនួនឱ្យបំរើការងារផ្ទាល់ ទោះបីមន្ត្រីនោះពុំមែនជាមន្ត្រីក្របខ័ណ្ឌក៏ដោយ ។ ក្នុងករណីនេះ សាមីជនមានសិទ្ធិទទួលបៀវត្សជាធម្មតា តែគ្មានសិទ្ធិទទួលប្រាក់សោធននិវត្តន៍ទេ ហើយបញ្ចប់មុខតំណែងរបស់ខ្លួនតាមអាណត្តិរបស់ប្រធានស្ថាប័ន ។

**មាត្រា ៧២._**

អគ្គលេខាធិការដ្ឋានអាចប្រើប្រាស់បុគ្គលិកជាប់កិច្ចសន្យាដែលមានរយៈពេលយូរបំផុតមួយឆ្នាំ។ កិច្ចសន្យាអាចបន្តបាន តាមសេចក្ដីត្រូវការរបស់អគ្គលេខាធិការដ្ឋាន។

## ជំពូកទី ១១
## អន្តរប្បញ្ញត្តិ

**មាត្រា ៧៣._ ថ្មី**

គោលការណ៍និងល័ក្ខខ័ណ្ឌនៃការធ្វើសមាហរណកម្មក្របខ័ណ្ឌបច្ចុប្បន្នរបស់អ្នករាជការនៃក្រុមនីតិប្បញ្ញត្តិ ទៅក្នុងប្រភេទក្របខ័ណ្ឌឋានន្តរសក្តិ និងថ្នាក់ថ្មី ត្រូវកំណត់ដោយសេចក្តីសម្រេចរួមរបស់ប្រធានស្ថាប័នទាំងបី ។

បែបបទ និងនីតិវិធីនៃការធ្វើសមាហរណកម្មអ្នករាជការនៃក្រុមនីតិប្បញ្ញត្តិ ទៅក្នុងប្រភេទក្របខ័ណ្ឌ ឋានន្តរសក្តិ និងថ្នាក់ថ្មី ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានស្ថាប័ន ។

# ជំពូកទី ១២
# អវសានប្បញ្ញត្តិ

**មាត្រា ៧៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០១៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

*នស/រកម.០៤១៧.០០៧* **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ: ៤០៦ ស.ណ

**សំណៅ[illegible]ជាការចែកផ្សាយ**

រាជធានី[illegible] ថ្ងៃទី [illegible] ឆ្នាំ២០១៧

**[illegible]រាជរដ្ឋាភិបាល**

**ស៊យ សុខា**

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៣

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

ពរល.០៣.០២.០៦៩

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខៈ ៧២ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**[illegible] តាន់**